ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តបន្ទាយមានជ័យ

តុលាការរដ្ឋប្បវេណី

សំណុំរឿងរដ្ឋប្បវេណីលេខ ៧១៧

ចុះថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៩

សាលក្រមលេខ : ១៥ "ជ"/ ១៣៤

ចុះថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២០

# សាលក្រម

# តាងនាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងខេត្តបន្ទាយមានជ័យ

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី ២៧ ខែឧសភា ឆ្នាំ២០២០

## ចៅក្រមជំនុំជម្រះ

-លោក [redacted] ជាចៅក្រមសាលាដំបូងខេត្តបន្ទាយមានជ័យ

## ក្រឡាបញ្ជី

-កញ្ញា [redacted] ជាក្រឡាបញ្ជីសាលាដំបូងខេត្តបន្ទាយមានជ័យ

**ដើមចោទ**

ឈ្មោះ ៖ [redacted] **សារួន** ភេទស្រី កើតថ្ងៃទី ០១ ខែសីហា ឆ្នាំ១៩៨៧ សញ្ជាតិខ្មែរ ។

អាសយដ្ឋាន ៖ [redacted] ។

**សហមេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ**

១.លោក ៖ [redacted] **សុធា** អត្តលេខ ៦១២

ការិយាល័យក្រុមមេធាវី ៖ [redacted]

អាសយដ្ឋានការិយាល័យមេធាវី ៖ [redacted] ។

២.លោក ៖ [redacted] អត្តលេខ ១៨៧៥T

ការិយាល័យក្រុមមេធាវី ៖ [redacted]

អាសយដ្ឋានការិយាល័យមេធាវី ៖ [redacted] ។

**ចុងចម្លើយ**

ឈ្មោះ ៖ [redacted] **ស៊ីណា** ភេទប្រុស កើតថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ១៩៧៨ សញ្ជាតិខ្មែរ ។

អាសយដ្ឋាន ៖ [redacted] ។



Scanned with CamScanner

# អង្គហេតុ និង ចំណុចវិវាទ

## ក.ខ្លឹមសារនៃសាលក្រមដែលទាមទារដោយភាគី

### ក.១ ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ

១-ឱ្យនាងខ្ញុំ និងចុងចម្លើយជាប្តីផ្តាច់អនីតិសង្វាសពីគ្នា ។

២-ឱ្យដើមចោទជាអ្នកមានសិទ្ធិគ្រប់គ្រងជាអ្នកមានអំណាចមេបាលើកូន ០៤ នាក់ ។

៣-ឱ្យចុងចម្លើយជួយបង់ប្រាក់ចិញ្ចឹមកូន ៤ នាក់ ១ ខែ ៤.០០០.០០០ (បួនលាន) រៀល ។

៤-ឱ្យបែងចែកទ្រព្យរួម ជាពីរចំណែកស្មើគ្នា ។

៥-ឱ្យដើមចោទ និងចុងចម្លើយទទួលខុសត្រូវលើបំណុលរួម ។

### ក.២ ខ្លឹមសារនៃសាលក្រមដែលដើមបណ្តឹងតបទាមទារឱ្យតុលាការចេញ

១-សុំបញ្ឈប់ការរស់នៅបែបអនីតិសង្វាសពីប្រពន្ធឈ្មោះ [redacted] សារ៉ន ។

២-សុំបែងចែកទ្រព្យសម្បត្តិរួម មានរថយន្តដឹកដី ចំនួន ០១ គ្រឿង , ត្រាក់ទ័រចំនួន ០១ គ្រឿង និងម៉ូតូចំនួន ៣ គ្រឿង គឺម៉ូតូម៉ាក ហុងដា C-125 ស៊េរីឆ្នាំ២០១៩ ចំនួន ០១ គ្រឿង , សង់ C-100 ចំនួន ០១ គ្រឿង និងម៉ាកឌុប ៥០ ចំនួន ០១ គ្រឿង ។

៣-សុំឱ្យចុងបណ្តឹងតបសងបំណុលម្នាក់ពាក់កណ្តាល ជំពាក់ធនាគារប្រៃសណីយ៍កម្ពុជា ចំនួន **៥២.៨០០ (ហ្រាំម៉ឺន ពីរពាន់ប្រាំបីរយ) ដុល្លារអាមេរិក** និងជំពាក់អ្នកផ្សេងៗទៀតរាយរង ។

៤-អាហារកិច្ចចិញ្ចឹមកូន គឺខ្ញុំបាទជាអ្នកផ្តល់ឱ្យតាមលទ្ធភាព ។

## ខ.ដំណើររឿងក្តី និង ចំណុចវិវាទ

### ខ.១ ការសង្ខេបអំពីរឿងក្តី

នៅក្នុងរឿងក្តីនេះ ដើមចោទ និងចុងចម្លើយបានរៀបការជាមួយគ្នាតាមប្រពៃណីកាលពីអំឡុងខែកុម្ភៈ ឆ្នាំ២០០៥ តែមិនបានទៅចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាទេ ។ ក្នុងអំឡុងពេលរួមរស់ជាមួយគ្នាជាប្តីប្រពន្ធអនីតិសង្វាស ដើមចោទ និងចុងចម្លើយ មានកូនជាមួយគ្នាចំនួន ៤ នាក់ និងមានទ្រព្យសម្បត្តិ ព្រមទាំងបំណុលរួមគ្នាមួយចំនួន ។ ក្រោយមកដើមចោទ និងចុងចម្លើយ ចាប់ផ្តើមមានបញ្ហាជាមួយគ្នា រហូតដល់ថ្ងៃទី ១៩ ខែមិថុនា ឆ្នាំ២០១៩ ដើមចោទបានដាក់ពាក្យបណ្តឹងសុំផ្តាច់អនីតិសង្វាសមកសាលាដំបូងខេត្តបន្ទាយមានជ័យ ។

### ខ.២ អង្គហេតុដែលគ្មានវិវាទ

**ខ.២.១** ដើមចោទ និងចុងចម្លើយបានរៀបអាពាហ៍ពិពាហ៍តាមប្រពៃណីជាមួយគ្នា តែមិនបាននាំគ្នាទៅសុំចុះសំបុត្រអាពាហ៍ពិពាហ៍ពីអាជ្ញាធរមានសមត្ថកិច្ចទេ ។

**ខ.២.២** ដើមចោទបានអះអាងថាខ្លួនដាក់សុំផ្តាច់អនីតិសង្វាសពីចុងចម្លើយសារតែចុងចម្លើយ និងខ្លួនរស់នៅមិនចុះសម្រុងជាមួយគ្នា ហើយចុងចម្លើយបានប្រើប្រាស់ហិង្សាមកលើខ្លួន ព្រមទាំងជេរប្រមាថមើលងាយដើមចោទ និងឪពុកម្តាយរបស់ដើមចោទ ហើយមានស្រីក្រៅផងដែរ ។ នៅក្នុងអំឡុងខែមេសា ឆ្នាំ២០១៩ ចុងចម្លើយចាប់ផ្តើមរស់នៅបែកផ្ទះគ្នាជាមួយដើមចោទ ។ ចំណែកចុងចម្លើយវិញបានអះអាងតបវិញថា ខ្លួនយល់ព្រម



Scanned with CamScanner

-និង ម៉ូតូចំនួន ០៣ ( បី) គ្រឿង ។

១.២ ការអះអាងពីទំហំនៃទ្រព្យសម្បត្តិរួមរបស់ចុងចម្លើយរួមមាន ៖

-រថយន្តដឹកដីចំនួន ០១ គ្រឿង ។

-ត្រាក់ទ័រចំនួន ០១ គ្រឿង

-ម៉ូតូចំនួន ៣ គ្រឿង គឺម៉ូតូម៉ាក ហុងដា C-125 ស៊េរីឆ្នាំ២០១៩ ចំនួន ០១ គ្រឿង , សង់ C-100 ចំនួន ០១ គ្រឿង និងម៉ាកគុប ៥០ ចំនួន ០១ គ្រឿង ។

២-ដើមចោទទាមទារឱ្យបែងចែកបំណុលរួមជាពីរចំណែកស្មើគ្នា ចុងចម្លើយក៏ឯកភាពលើការទាមទារឱ្យបែងចែក តែការអះអាងលើទំហំបំណុល មានផ្សេងគ្នាគឺ ៖

**២.១** ការអះអាងលើបំណុលរួមរបស់ដើមចោទ សរុបមានចំនួន **៣៤០.០០០ (សាមសិបបួនម៉ឺន) បាត និង ១.៣០០ (មួយពាន់បីរយ) ដុល្លារអាមេរិក** ។

**២.២** ការអះអាងលើបំណុលរួមរបស់ចុងចម្លើយ សរុបមានចំនួន **៥២.៨០០ (ប្រាំម៉ឺនពីរពាន់ ប្រាំបីរយ) ដុល្លារអាមេរិក** ។

## គ.ភស្តុតាង

### គ.១ ភស្តុតាងដាក់បញ្ចូលដោយដើមចោទ និងមេធាវីតំណាងដោយអាណត្តិ

#### គ.១.១ ភស្តុតាងជាឯកសារ

១.ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍លេខ ៣០ ប.ប្រក.ឃ.គ.ម ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០០៥ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំគយម៉ែង ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ (ថតចម្លង ចំនួន ០១ ច្បាប់) ។

២.ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ចុះថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០០៥ របស់ឈ្មោះ [redacted] **សារួន** និងឈ្មោះ [redacted] **ស៊ីណា** (ថតចម្លង ចំនួន ០១ ច្បាប់) ។

៣.សំបុត្របញ្ជាក់កំណើតលេខ ១៥២ សៀវភៅបញ្ជាក់កំណើតលេខ ០២/២០១០ ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១០ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ (ថតចម្លង ចំនួន ០១ ច្បាប់) ។

៤.សំបុត្របញ្ជាក់កំណើតលេខ ១៥៣ សៀវភៅបញ្ជាក់កំណើតលេខ ០២/២០១០ ចុះថ្ងៃទី ២៩ ខែមីនា ឆ្នាំ២០១០ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ (ថតចម្លង ចំនួន ០១ ច្បាប់) ។

៥.សំបុត្រកំណើតលេខ ៩៨ សៀវភៅកំណើតលេខ ០២/២០១២ ចុះថ្ងៃទី ២១ ខែកញ្ញា ឆ្នាំ២០១២ ចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ (ថតចម្លង ចំនួន ០១ ច្បាប់) ។

៦.ប័ណ្ណសុខភាពកុមារា ឈ្មោះ [redacted] **រាយុទ្ធ** កើតថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៨ ចេញដោយមណ្ឌលសុខភាពឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ (ថតចម្លង ចំនួន ០១ ច្បាប់ ) ។



Scanned with CamScanner

៧.សៀវភៅគ្រួសារ បញ្ជីក៣ ក្បាលទី ៦ ទំព័រទី ១៧ អាសយដ្ឋានភូមិប្រឡាយហ្លួងក្រោម ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ចុះថ្ងៃទី ២១ ខែឧសភា ឆ្នាំ២០១២ ចេញដោយស្នងការនគរបាលខេត្តបន្ទាយមានជ័យ (ថតចម្លង ចំនួន ០១ ច្បាប់) ។

៨.តារាងសងប្រាក់ឥណទានទោល ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨ ចេញដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ខេមបូឌា ភីអិលស៊ី [redacted] សាខាខេត្តបន្ទាយមានជ័យ អតិថិជនឈ្មោះ [redacted] សារួន លើប្រាក់កម្ចីចំនួន ៣០.០០០ (បីម៉ឺន) បាត (ថតចម្លង ចំនួន ០១ ច្បាប់) ។

៩.តារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ចេញដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] សាខាស្រុកមង្គលបូរី-ឃុំឫស្សីក្រោក អតិថិជនឈ្មោះ [redacted] លួម លើប្រាក់កម្ចីចំនួន ៨០.០០០ (ប្រាំបីម៉ឺន) បាត (ថតចម្លង ចំនួន ០១ ច្បាប់) ។

១០.តារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៨ ចេញដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] អ្នកខ្ចីឈ្មោះ [redacted] លួម លើប្រាក់កម្ចីចំនួន ២០០.០០០ (ម្ភៃម៉ឺន) បាត (ថតចម្លង ចំនួន ០១ ច្បាប់) ។

**គ.១.២ ភស្តុតាងជាសាក្សី**

១.ឈ្មោះ [redacted] **តាំងយី** ភេទស្រី អាយុ ២១ ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិ [redacted] ។

២.ឈ្មោះ [redacted] លួម ភេទស្រី អាយុ ៥៧ ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋានបច្ចុប្បន្ននៅភូមិ [redacted] ។

**គ.២ ភស្តុតាងដាក់បញ្ចូលដោយចុងចម្លើយ**

**គ.២.១ ភស្តុតាងជាឯកសារ**

១.កិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ រវាងធនាគារ [redacted] សាខាខេត្តបន្ទាយមានជ័យ និងអ្នកខ្ចីប្រាក់ឈ្មោះ [redacted] **ស៊ីណា** និងប្រពន្ធឈ្មោះ [redacted] **សារួន** លើទឹកប្រាក់កម្ចីចំនួន **៥២.៨០០ (ប្រាំម៉ឺន ពីរពាន់ ប្រាំបីរយ) ដុល្លារអាមេរិក** ។ (ថតចម្លង ចំនួន ០១ ច្បាប់)

២.តារាងកាលវិភាគសងប្រាក់ (ឥណទានខ្នាតមធ្យម) ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ធនាគារ [redacted] សាខាខេត្តបន្ទាយមានជ័យ ។ (ថតចម្លង ចំនួន ០១ ច្បាប់)

៣.កិច្ចសន្យាដាក់បញ្ចាំ ចុះថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ធនាគារ [redacted] សាខាខេត្តបន្ទាយមានជ័យ ។ (ថតចម្លង ចំនួន ០១ ច្បាប់)

៤.តារាងកាលវិភាគសងប្រាក់ទោល ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ២០១៨ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ភីអិលស៊ី [redacted] សាខាខេត្តបន្ទាយមានជ័យ អតិថិជនឈ្មោះ [redacted] កញ្ញា លើប្រាក់កម្ចីចំនួន ៣០.០០០ (បីម៉ឺន) បាត ។ (ថតចម្លង ចំនួន ០១ ច្បាប់)

៥.កិច្ចសន្យារក្សាការសម្ងាត់ព័ត៌មាន ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១៨ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] សាខាខេត្តបន្ទាយមានជ័យ ដែលមានអតិថិជនឈ្មោះ [redacted] សារួន និងឈ្មោះ [redacted] កញ្ញា ។



Scanned with CamScanner

៦.កិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១៨ របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] សាខាខេត្តបន្ទាយមានជ័យ ដែលមានអតិថិជនឈ្មោះ [redacted] សារួន និងឈ្មោះ [redacted] កញ្ញា លើប្រាក់កម្ចីចំនួន ៦០.០០០ (ហុកសិបម៉ឺន) បាត ។

៧.បណ្ណសម្គាល់យានយន្ត រថយន្តម៉ាក HINO TRUCK ប្រភេទដឹកទំនិញធុនធំ ពណ៌ស ផលិតឆ្នាំ ១៩៨១ កម្មសិទ្ធិករឈ្មោះ [redacted] ស៊ីណា ផ្លាកលេខ **បន្ទាយមានជ័យ 3A-1233** ។

**គ.២.២ ភស្តុតាងជាសាក្សី**

១.ឈ្មោះ [redacted] ណាង ភេទប្រុស អាយុ ៥៥ ឆ្នាំ រស់នៅភូមិ [redacted] ។ ទូរស័ព្ទលេខ ០១៧ ៧០៥ ១២៣ ។

២.ឈ្មោះ [redacted] កូស៊ីន ភេទស្រី អាយុ ៣០ ឆ្នាំ រស់នៅភូមិ [redacted] ។ ទូរស័ព្ទលេខ ០១៧ ៧០៥ ១២៣ ។

៣.ឈ្មោះ [redacted] រី ភេទស្រី អាយុ ៣៥ ឆ្នាំ រស់នៅភូមិ [redacted] ។

៤.ឈ្មោះ [redacted] ស៊ីនួន ភេទស្រី អាយុ ៣៩ ឆ្នាំ រស់នៅភូមិ [redacted] ។

៥.ឈ្មោះ [redacted] រឿន ភេទប្រុស អាយុ ៧៩ ឆ្នាំ រស់នៅភូមិ [redacted] ។

៦.ឈ្មោះ [redacted] ផន ភេទស្រី អាយុ ៧០ ឆ្នាំ រស់នៅភូមិប្រឡាយហ្លួងក្រោម ឃុំឬស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ។

៧.ឈ្មោះ [redacted] សាវ៉ាក់ ភេទប្រុស អាយុ ៥៥ ឆ្នាំ រស់នៅភូមិ [redacted] ។

## សំអាងហេតុ

ក្រោយពីបានស្ដាប់សេចក្ដីថ្លែងការណ៍របស់ដើមចោទ , មេធាវីតំណាងដោយអាណត្តិឱ្យដើមចោទ , ចុងចម្លើយ និងសាក្សីនៅដំណាក់កាលនៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល និងបានបញ្ចប់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចមក តុលាការយល់ឃើញថា៖

### ក. ការវិនិច្ឆ័យអំពីការទាមទារ

**ក.១** ដើមចោទ បានដាក់ពាក្យបណ្ដឹងផ្ដាច់អនីតិសង្វាសពីចុងចម្លើយ ស្របពេលដែលដើមចោទ និងចុងចម្លើយ មានអាសយដ្ឋានស្ថិតក្នុងខេត្តបន្ទាយមានជ័យ ។ **ឃើញថា** សាលាដំបូងខេត្តបន្ទាយមានជ័យ ជាតុលាការដែលមានសមត្ថកិច្ចលើបណ្ដឹងទាមទារនេះ អាចលើកយកមកវិនិច្ឆ័យចេញសាលក្រមបាន ។

**ក.២** ការផ្សះផ្សារបស់តុលាការនៅគ្រប់នីតិវិធីពុំទទួលបានលទ្ធផល ដោយគូភាគីនៅតែមិនអាចសះជានឹងគ្នាបាន ។

**ក.៣** ផ្អែកតាមអង្គហេតុដែលគ្មានវិវាទ និងចំណុចវិវាទ តុលាការទទួលស្គាល់ការទាមទារផ្ដាច់អនីតិសង្វាសរបស់ដើមចោទ និងចុងចម្លើយ ដោយសារតែទំនាក់ទំនងអាពាហ៍ពិពាហ៍របស់ដើមចោទ និងចុងចម្លើយត្រូវបានបែកបាក់ ហើយគ្មានសង្ឃឹមថា នឹងអាចធ្វើបដិទានឡើងវិញបាន ។ **ដូច្នេះហើយ គប្បីតុលាការពិចារណា និងសម្រេចតាមការទាមទាររបស់ដើមចោទ និងចុងចម្លើយ ។**

ក.៤ អំពីកូន ដើមចោទ និងចុងចម្លើយមានកូនចំនួន ០៤ (បួន) នាក់ ដែលកូននេះ ដើមចោទ និងចុងចម្លើយបានព្រមព្រៀងគ្នា ប្រគល់ទៅឱ្យដើមចោទជាអ្នកមានសិទ្ធិគ្រប់គ្រង និងមានអំណាចមេបា ដោយចុងចម្លើយមិនសុំទៅសួរសុខទុក្ខកូន ឬ យកកូនទៅលេងទេ ចំណែកសោហ៊ុយចាំបាច់សម្រាប់ចិញ្ចឹមកូន ចុងចម្លើយសុំផ្តល់ឱ្យតាមលទ្ធភាព ដោយដើមចោទក៏បានយល់ព្រម **គប្បីតុលាការពិចារណា និងសម្រេចតាមការព្រមព្រៀងរបស់គូភាគី ។**

ក.៥ អំពីទ្រព្យសម្បត្តិរួម ដើមចោទ និងចុងចម្លើយបានអះអាងផ្សេងៗពីគ្នា ។ ក្រោយពីបានស្តាប់ការអះអាងរបស់គូភាគី និងភស្តុតាង នៅក្នុងសំណុំរឿង តុលាការពិនិត្យឃើញថា ទ្រព្យសម្បត្តិរួមរបស់គូភាគីរួមមាន ៖

-រថយន្តមួយគ្រឿង ម៉ាក ហ៊ីណូដ្រាក់ (HINO TRUCK) ប្រភេទដឹកទំនិញធុនធំ ពណ៌ស ផ្លាកលេខ បន្ទាយមានជ័យ 3A-1233 ផលិតឆ្នាំ ១៩៩១ មានកម្មសិទ្ធិករឈ្មោះ [redacted] ស៊ីណា ។

-ត្រាក់ទ័រ ចំនួន ០១ គ្រឿង ។

-ម៉ូតូចំនួន ០៣ គ្រឿង រួមមានម៉ូតូម៉ាក ហុងដា C125 ស៊េរីឆ្នាំ ២០១៩, ម៉ូតូម៉ាក C-100 ចំនួន ០១ គ្រឿង និងម៉ូតូម៉ាក គុប ៥០ ចំនួន ០១ គ្រឿង ។

-ដីនិងផ្ទះស្ថិតនៅក្នុងភូមិប្រឡាយហ្លួងក្រោម ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០២០៩០៨-០៣០៩ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១១ ។

គប្បីតុលាការសម្រេចបែងចែកទ្រព្យសម្បត្តិរួមខាងលើជាពីរចំណែកស្មើគ្នា លើកលែងតែ "ម៉ូតូម៉ាក ហុងដា C125 ស៊េរីឆ្នាំ ២០១៩" ដែលដើមចោទបានធ្វើការអះអាងនៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើក ទី ៣ កាលពីថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៩ ថាខ្លួនបានលក់ម៉ូតូនោះបាត់ទៅហើយ ដើម្បីដោះស្រាយជីវភាពគ្រួសារ និងដើម្បីចិញ្ចឹមកូនៗទាំងបួននាក់ គប្បីតុលាការពិចារណាមិនសម្រេចយកម៉ូតូនេះមកបែងចែកតាមការទាមទារទៀតទេ ។ តាមបញ្ញត្តិនៃច្បាប់ "ប្តីប្រពន្ធត្រូវ ទទួលខុសត្រូវដោយសាមគ្គីភាពចំពោះភាគពួកិច្ចដែលកំណត់ដូចខាងក្រោម ៖ ក.សោហ៊ុយដើម្បីរក្សាជីវភាពរួមប្តីប្រពន្ធ និងសោហ៊ុយដើម្បីការអប់រំ ឬ ព្យាបាល ថែរទាំកូនជាអាទិ៍" ។

ក.៦ អំពីបំណុលរួម គូភាគីបានធ្វើការអះអាងផ្សេងពីគ្នាដូចខាងក្រោម ៖

**ក.៦.១ បំណុលរួម អះអាងដោយភាគីដើមចោទ រួមមាន ៖**

១.ជំពាក់ប្រាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ខេមបូឌាភីអិលស៊ី [redacted] សាខាខេត្តបន្ទាយមានជ័យ ចំនួន ៣០.០០០ (បីម៉ឺន) បាត ។

២.ជំពាក់ប្រាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ចំនួន ៨០.០០០ (ប្រាំបីម៉ឺន) បាត ។

៣.ជំពាក់ប្រាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ចំនួន ២០០.០០០ (ម្ភៃម៉ឺន) បាត ។

៤.ជំពាក់ប្រាក់ម្តាយដើមចោទ ចំនួន ១.៣០០ (មួយពាន់ បីរយ) ដុល្លារអាមេរិក និង ៣០.០០០ (បីម៉ឺន) បាត ។

តុលាការពិនិត្យឃើញថា បំណុលរួម ដែលភាគីដើមចោទបានអះអាង តុលាការសម្រេចមិនទទួលស្គាល់ឡើយ ព្រោះតាមរយៈការពិនិត្យភស្តុតាងជាឯកសារអំពីបំណុលដែលដើមចោទអះអាងខាងលើរួមមាន ៖

១.ជំពាក់ប្រាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] សាខាខេត្តបន្ទាយមានជ័យ ចំនួន ៣០.០០០ (បីម៉ឺន) បាត មានតារាងសងប្រាក់ឥណទានទោល ចុះថ្ងៃទី ២០

ខែធ្នូ ឆ្នាំ២០១៨ មានឈ្មោះនិងស្នាមមេដៃអ្នកខ្ចីតែម្នាក់ គឺ ដើមចោទឈ្មោះ [redacted] សារ៉ូន ដោយពុំមានការចូលរួមខ្ចីពីចុងចម្លើយឈ្មោះ [redacted] ស៊ីណា ទេ ។

២.ជំពាក់ប្រាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ចំនួន ៨០.០០០ (ប្រាំបីម៉ឺន) បាត មានតារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ ជាបំណុលរបស់ឈ្មោះ [redacted] ល្អម ដែលត្រូវជាម្តាយបង្កើតរបស់ ដើមចោទ មិនមែនជាបំណុលរួមរបស់ដើមចោទ និងចុងចម្លើយទេ ។

៣.ជំពាក់ប្រាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ចំនួន ២០០.០០០ (ម្ភៃម៉ឺន) បាត មានតារាងកាលវិភាគសងប្រាក់ ចុះថ្ងៃទី ០១ ខែតុលា ឆ្នាំ២០១៨ ជាបំណុលរបស់ឈ្មោះ [redacted] ល្អម ដែលត្រូវជាម្តាយបង្កើតរបស់ដើមចោទ មិនមែនជាបំណុលរួមរបស់ដើមចោទ និងចុងចម្លើយទេ ។

៤.ជំពាក់ប្រាក់ម្តាយដើមចោទ ចំនួន ១.៣០០ (មួយពាន់ បីរយ) ដុល្លារអាមេរិក និង ៣០.០០០ (បីម៉ឺន) បាត ពុំមានភស្តុតាងណាមួយអាចបញ្ជាក់ឱ្យតុលាការឃើញថា ជាបំណុលរួមដែលដើមចោទ និងចុងចម្លើយបានខ្ចីរួមគ្នាទេ គ្រាន់តែជាបំណុលដែលដើមចោទបានលើកឡើងដោយឯកតោភាគី ។

តាមបញ្ញត្តិនៃច្បាប់ «កាតព្វកិច្ច និងករណីកិច្ចផ្សេងៗទៀត ដែលប្តីប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជាលាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុលនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្តី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីប្រពន្ធ ឬ ប្តីម្ខាងទៀត នៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍» ។

**ក.៦.២ បំណុលរួម អះអាងដោយភាគីចុងចម្លើយ រួមមាន ៖**

១.ជំពាក់ធនាគារ [redacted] ចំនួន ៥២.៨០០ (ប្រាំម៉ឺន ពីរពាន់ ប្រាំបីរយ) ដុល្លារអាមេរិក ។

២.ជំពាក់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ចំនួន ៦០.០០០ (ប្រាំមួយម៉ឺន) បាត ។

៣.ខ្ចីពីបងថ្លៃឈ្មោះ [redacted] សារ៉ាក់ ចំនួន ១០០០០០ (ដប់ម៉ឺន) បាត ។

៤.ខ្ចីពីអ្នកលក់ត្រាក់ទ័រឈ្មោះ [redacted] ចំនួន ៣០០០០ (បីម៉ឺន) បាត ។

៥.ខ្ចីពីឈ្មោះ [redacted]ថន ចំនួន ៣៥០០០ (បីម៉ឺន ប្រាំពាន់) បាត ។

៦.ខ្ចីពីឈ្មោះ [redacted] ឈួង ចំនួន ១០០០០ (មួយម៉ឺន) បាត ។

៧.ខ្ចីពី [redacted] ចំនួន ១៥០០០ (មួយម៉ឺន ប្រាំពាន់) បាត ។

៨.ខ្ចីពី [redacted] ចំនួន ១៥០០ (មួយពាន់ ប្រាំរយ) ដុល្លារអាមេរិក ។

តុលាការពិនិត្យឃើញថា បំណុលរួម ដែលភាគីចុងចម្លើយបានអះអាង តុលាការសម្រេចទទួលស្គាល់តែបំណុលរួមចំណុច ១ នៃការអះអាងរបស់ចុងចម្លើយ ក្រៅពីនោះ តុលាការមិនទទួលស្គាល់ឡើយ ព្រោះតាមរយៈការពិនិត្យភស្តុតាងជាឯកសារអំពីបំណុលដែលចុងចម្លើយអះអាងខាងលើរួមមាន ៖

១.ជំពាក់ធនាគារ [redacted] ចំនួន ៥២.៨០០ (ប្រាំម៉ឺន ពីរពាន់ ប្រាំបីរយ) ដុល្លារ អាមេរិក មានកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១៨ មានស្នាមមេដៃអ្នកខ្ចីឈ្មោះ [redacted] ស៊ីណា និងឈ្មោះ [redacted] សារ៉ូន ។

២.ជំពាក់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ [redacted] ចំនួន ៦០.០០០ (ប្រាំមួយម៉ឺន) បាត មានកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ២០១៨ មានស្នាមមេដៃអ្នកខ្ចីឈ្មោះ [redacted] សារ៉ូន ចំនួន ៣០.០០០ (បីម៉ឺន) បាត



Scanned with CamScanner

និងអ្នកខ្ចីឈ្មោះ [redacted] កញ្ញា ចំនួន ៣០.០០០ (បីម៉ឺន) បាត ដោយពុំមានចុងចម្លើយឈ្មោះ [redacted] ស៊ីណា ចូលរួមខ្ចីជាមួយទេ ។

៣.ចំពោះបំណុលផ្សេងៗ ដែលចុងចម្លើយបានអះអាងរួមមាន ៖

-ខ្ចីពីបងថ្លៃឈ្មោះ [redacted] សារ៉ាក់ ចំនួន ១០០០០០ (ដប់ម៉ឺន) បាត

-ខ្ចីពីអ្នកលក់ត្រាក់ទ័រឈ្មោះ [redacted] ទី ចំនួន ៣០០០០ (បីម៉ឺន) បាត

-ខ្ចីពីឈ្មោះ ជាង[redacted] ចំនួន ៣៥០០០ (បីម៉ឺន ប្រាំពាន់) បាត

-ខ្ចីពីឈ្មោះ [redacted] ឈ្យួង ចំនួន ១០០០០ (មួយម៉ឺន) បាត

-ខ្ចីពី ថៃ[redacted] ចំនួន ១៥០០០ (មួយម៉ឺន ប្រាំពាន់) បាត

-និងខ្ចីពី គ្រូ[redacted] ចំនួន ១៥០០ (មួយពាន់ ប្រាំរយ) ដុល្លារអាមេរិក ។

បំណុលទាំងអស់នេះ សុទ្ធតែជាការអះអាងដោយឯកតោភាគីរបស់ចុងចម្លើយ ថាជាបំណុលរួមប្ដីប្រពន្ធព្រោះដើមចោទមានការយល់ព្រមលើការខ្ចីប្រាក់នេះ ប៉ុន្តែពុំមានភស្តុតាងណាមួយ បញ្ជាក់ឱ្យតុលាការឃើញថា មានការយល់ព្រមពីដើមចោទដូចការអះអាងរបស់ចុងចម្លើយទេ ។ តាមបញ្ញត្តិនៃច្បាប់ "កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្ដីប្រពន្ធទាំងសងខាងបានព្រមព្រៀងតាមលិខិតជា លាយលក្ខណ៍អក្សរជាមួយម្ចាស់បំណុលនៅក្នុងអំឡុងពេលអាពាហ៍ពិពាហ៍ ឬ កាតព្វកិច្ច និងករណីយកិច្ចផ្សេងៗទៀត ដែលប្ដី ឬ ប្រពន្ធណាម្ខាងបានទទួលបន្ទុក ដោយមានការយល់ព្រមជាលាយលក្ខណ៍អក្សរពីប្រពន្ធ ឬ ប្ដីម្ខាងទៀត នៅក្នុង អំឡុងពេលអាពាហ៍ពិពាហ៍" ។

**ក.៧** អំពីសាក្សីដែលចុងចម្លើយបានដាក់ពាក្យសុំបញ្ចូលសាក្សី ចុះថ្ងៃទី **២១ ខែមករា ឆ្នាំ២០២០** តុលាការពិចារណា និងសម្រេចមិនធ្វើសាកសួរឡើយ ដោយសារតែចុងចម្លើយបានដាក់ពាក្យសុំបញ្ចូលសាក្សី នៅក្រោយពេលដែលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ត្រូវបានបញ្ចប់ហើយ ។ "នៅក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលលើកទី ៣ នៅថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៩ តុលាការបានប្រកាសបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល និងកំណត់ឱ្យគូភាគីត្រូវដាក់បញ្ចូលភស្តុតាងជាឯកសារ និងសាក្សី ឱ្យបានមុនថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១៩ ជាកំហិត" ។

**ខ. ស្ដីពីបន្ទុកនៃប្រាក់ប្រដាប់ក្ដី**

ចំពោះប្រាក់ប្រដាប់ក្ដី គប្បីតុលាការពិចារណា និងសម្រេចឱ្យដើមចោទជាអ្នកទទួលបន្ទុក ។

## សេចក្ដីសម្រេចបញ្ចប់

**១-**ឱ្យដើមចោទឈ្មោះ [redacted] **សារួន** ភេទស្រី កើតថ្ងៃទី ០១ ខែសីហា ឆ្នាំ១៩៨៧ សញ្ជាតិខ្មែរ និងចុងចម្លើយឈ្មោះ [redacted] **ស៊ីណា** ភេទប្រុស កើតថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ១៩៧៨ សញ្ជាតិខ្មែរ ផ្តាច់អនីសង្វាសនឹងគ្នា ។

**២-**ឱ្យដើមចោទឈ្មោះ [redacted] **សារួន** មានសិទ្ធិគ្រប់គ្រង និងសិទ្ធិអំណាចមេបាលើកូនទាំង ០៤ នាក់ គឺ ៖

-ទី១ ឈ្មោះ [redacted] សុធី ភេទប្រុស កើតថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០០៥ ។

-ទី២ ឈ្មោះ [redacted] សុខហែម ភេទប្រុស កើតថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០០៨ ។

-ទី៣ ឈ្មោះ [redacted] រៃយ៉ា ភេទប្រុស កើតថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ២០១២

-ទី ៤ ឈ្មោះ [redacted] រៃយុទ្ធ ភេទប្រុស កើតថ្ងៃទី ០៩ ខែតុលា ឆ្នាំ២០១៨ ។



Scanned with CamScanner

៣-ឱ្យចុងចម្លើយឈ្មោះ [redacted] **ស៊ីណា** ជួយផ្តល់ប្រាក់ចិញ្ចឹមកូនទាំង ០៤ (បួន) នាក់ តាមលទ្ធភាព ។

៤-បែងចែកទ្រព្យសម្បត្តិរួមជា ០២ (ពីរ) ចំណែកស្មើគ្នា រួមមាន ៖

-រថយន្តមួយគ្រឿង ម៉ាក ហ៊ីណូត្រាក់ (HINO TRUCK) ប្រភេទដឹកទំនិញធុនធំ ពណ៌ស ផ្លាកលេខ បន្ទាយមានជ័យ 3A-1233 ផលិតឆ្នាំ ១៩៩១ មានកម្មសិទ្ធិករឈ្មោះ [redacted] **ស៊ីណា** ។

-ត្រាក់ទ័រ ចំនួន ០១ គ្រឿង ។

-ម៉ូតូចំនួន ០២ គ្រឿង រួមមាន ម៉ូតូម៉ាក C-100 ចំនួន ០១ គ្រឿង និងម៉ូតូម៉ាក គុប ៥០ ចំនួន ០១ គ្រឿង ។

-ដីនិងផ្ទះស្ថិតនៅក្នុងភូមិប្រឡាយហ្លួងក្រោម ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ០១០២០៩០៨-០៣០៩ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ២០១១ ។

៥-ឱ្យដើមចោទឈ្មោះ [redacted] **សារួន** និងចុងចម្លើយឈ្មោះ [redacted] **ស៊ីណា** ទទួលបន្ទុករួមគ្នាលើបំណុលដែលបានខ្ចីពី [redacted] ចំនួន **៥២.៨០០ (ប្រាំម៉ឺនពីរពាន់ប្រាំបីរយ) ដុល្លារអាមេរិក មានកិច្ចសន្យាខ្ចីប្រាក់ ចុះថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ២០១៨** ។

៦-ច្រានចោលការទាមទារផ្សេងពីនេះ របស់ដើមចោទឈ្មោះ [redacted] **សារួន** និងចុងចម្លើយឈ្មោះ [redacted] **ស៊ីណា** ។

៧-ប្រាក់ប្រដាប់ក្តី និងប្រាក់ពន្ធផ្សេងៗជាបន្ទុករបស់ដើមចោទ ។

សាលក្រមនេះ ត្រូវបានប្រកាស នៅសវនាការជាសាធារណៈ នៅថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២០ ។ ក្នុងករណីប្តឹងឧទ្ធរណ៍ ត្រូវតែធ្វើឡើងក្នុងរយៈពេល ០១ ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ ។

ថ្ងៃ សុក្រ ១៥កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

បន្ទាយមានជ័យ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២០

**ចៅក្រម**

ហត្ថលេខា និងត្រា [redacted]

---

បានឃើញ

**ចៅក្រម**

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃ សុក្រ ១៥កើត ខែជេស្ឋ ឆ្នាំជូត ទោស័ក ព.ស២៥៦៤

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner